២-ចំពោះបទល្មើសជលផលថ្នាក់ទី ២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅបី(៣)ឆ្នាំ និង/ ឬ ពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅហាសិបលាន(៥០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

៣-ចំពោះបទល្មើសជលផលថ្នាក់ទី ៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ខែ ទៅមួយ (១) ឆ្នាំ ឬ ពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ទៅប្រាំលាន (៥.០០០.០០០) រៀល ។ វត្ថុតាងទាំងអស់អាចត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

៤-ការពិន័យអន្តរការណ៍ ការបំផ្លាញចោល ការដកហូត ឬ ការព្យួរកិច្ចព្រមព្រៀង ឬ លិខិតអនុញ្ញាត ។

តម្លៃទីផ្សារនៃផល ផលិតផលជលផល ឧបករណ៍នេសាទ និងកម្រិតសមាមាត្រនៃថ្លៃឈ្នួលនេសាទជាមូលដ្ឋានសម្រាប់ធ្វើការពិន័យ ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តឯកភាពទូទាំងប្រទេស ។

**មាត្រា ៩០.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសជលផលធ្វើឱ្យប៉ះពាល់ខូចខាតដល់អេកូឡូស៊ីជលផលនៅក្នុងដែននេសាទ ត្រូវចេញថ្លៃស្តារ ឬ ជួសជុលការខូចខាតឱ្យមានលក្ខខណ្ឌដូចដើមឡើងវិញ ។

**មាត្រា ៩១.-**

រដ្ឋបាលជលផលអាចចេញលិខិតព្រមាន ចំពោះសកម្មភាពល្មើសនៅក្នុងដែននេសាទដូចខាងក្រោម :

១-នេសាទជាលក្ខណៈគ្រួសារនៅកន្លែងនេសាទគ្រួសារដែលជាបឹងតូចៗ ស្ថិតនៅក្នុងនាទីឡូត៍នេសាទនារដូវបើកនេសាទ មិនគោរពទៅតាមបទបញ្ញាបច្ចេកទេសដែលកំណត់ដោយរដ្ឋបាលជលផល ។

២-ធ្វើវារីវប្បកម្មមិនតម្រូវឱ្យមានលិខិតអនុញ្ញាត តែមិនរាយការណ៍ឱ្យរដ្ឋបាលជលផល ។

៣-ប្រើប្រាស់លិខិតអនុញ្ញាតឱ្យធ្វើវារីវប្បកម្មមានលក្ខណៈអាជីវកម្មហួសសុពលភាព ។

**មាត្រា ៩២.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីពីរ (២) ដង ទៅបី (៣) ដងលើតម្លៃទីផ្សារនៃវត្ថុតាងពិតប្រាកដ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-នេសាទគ្រប់ប្រភេទដែលធ្វើឱ្យរាំងស្ទះចរាចរណ៍ត្រីចុះទៅតំបន់កបឹងទន្លេសាប ។

២-ចាប់ លក់ ទិញ ដឹកជញ្ជូន ប្រមូលផល កែច្នៃ និងធ្វើសន្និធិប្រភេទផល ផលិត-ផលជលផលពីធម្មជាតិដែលកំពុងរងគ្រោះថ្នាក់ ។

៣-បោះបង្គោលបង្កើតឡូត៍នេសាទថ្មី ឬ នេសាទជាលក្ខណៈឧស្សាហកម្ម នៅក្នុងកន្លែងនេសាទបម្រុង ។

៤-នាំចេញ នាំចូលប្រភេទផល ផលិតផលជលផលពីធម្មជាតិដែលកំពុងរងគ្រោះថ្នាក់ ។

៥-ប្រមូល ដឹកជញ្ជូន និងធ្វើសន្និធិឈើ អុស ធ្យូងប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាងជាលក្ខណៈអាជីវកម្ម ឬ ពាណិជ្ជកម្ម ។

ជនណាប្រព្រឹត្តបទល្មើសជលផលដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរ-ការណ៍ក្នុងមាត្រានេះ និងវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៩៣.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផល ជាប្រាក់ពីរ (២) ដងលើតម្លៃទីផ្សារនៃវត្ថុតាងពិតប្រាកដ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ធ្វើសន្និធិផល ផលិតផលជលផលគ្មានលិខិតអនុញ្ញាតលើស ឬ ខ្វះបរិមាណ និង/ ឬ ខុសយថាប្រភេទដែលកំណត់ក្នុងលិខិតអនុញ្ញាត ។

២-ផ្ទេរផលនេសាទនៅក្នុងដែននេសាទសមុទ្រក្នុងគោលបំណងនាំចេញដោយគ្មានការអនុញ្ញាត ។

៣-ដឹកជញ្ជូនផល ផលិតផលជលផលដោយគ្មានលិខិតអនុញ្ញាតលើសបរិមាណ ហួសសុពលភាព ខុសចំណុចទីតាំងនៃទិសដៅ និង/ ឬ ផ្លូវដែលត្រូវឆ្លងកាត់ ខុសមធ្យោបាយដែលកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៤-ដឹកជញ្ជូនផល ផលិតផលជលផលដោយពុំបានភ្ជាប់ប័ណ្ណបង់ប្រាក់បុព្វលាភ និង/ ឬ លិខិតអនុញ្ញាតឱ្យសន្និធិ ឬ ពុំបានកាត់ចេញនូវបរិមាណដឹកជញ្ជូនពីលិខិតអនុញ្ញាតឱ្យសន្និធិ ។

៥-នាំចេញ នាំចូលផល ផលិតផលជលផលគ្មានលិខិតអនុញ្ញាត ។

៦-នាំចេញ នាំចូលផល ផលិតផលជលផលគ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផល ។

៧-ធ្វើវារីវប្បកម្មគ្រប់ប្រភេទផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ដោយគ្មានលិខិតអនុញ្ញាត ខុសយថាប្រភេទ និង/ ឬ មិនអនុវត្តតាមបទបញ្ជាបច្ចេកទេស ។

៨-ទិញ លក់ផ្កាថ្ម ឬ ពពួកសំបកខ្យងខ្ចៅតាំងលំអដែលជាប្រភេទកម្រ ។

ជនណាប្រព្រឹត្តបទល្មើសជលផលដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ និងវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៩៥.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីមួយ (១) ដង ទៅពីរ (២) ដងលើតម្លៃទីផ្សារនៃវត្ថុតាងពិតប្រាកដ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-នេសាទដោយអួនអួសគូ ឬ អួនហ៊ុមរួមផ្សំភ្លើងធ្វើឱ្យត្រី ឬ វារីសត្វកុំ ។

២-នេសាទដោយឧបករណ៍ម៉ាញ់ នាម ជន មងក្រឡុក មងអួស ឈ្នាងអួស លៀស ឬ ខ្នៀនៅទឹកសាប និងឈ្នាងអួសគ្រែងឈាមនៅតំបន់ឆ្នេរសមុទ្រដែលអួស ឬ រុញដោយកម្លាំងម៉ាស៊ីនដោយគ្មានការអនុញ្ញាត ។

៣-នេសាទដោយប្រើឧបករណ៍ដាយចាប់ត្រី ឬ ដាយចាប់បង្កងខុសទីតាំងកំណត់របស់ឡូត៍ដាយចាប់ត្រី ឬ ដាយចាប់បង្កង ។

៤-នេសាទដោយអួនអួស ឬ ឈ្នាងអួសគ្រំក្រឡាហួលនៅក្រៅតំបន់អនុញ្ញាតឱ្យធ្វើនេសាទ ។

៥-ប្រើនាវានេសាទបរទេសដើម្បីធ្វើអាជីវកម្មនេសាទក្នុងដែននេសាទសមុទ្រកម្ពុជាមិនអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ។

៦-ប្រើនាវានេសាទបរទេសដើម្បីធ្វើអាជីវកម្មនេសាទនៅក្នុងដែននេសាទសមុទ្រកម្ពុជាគ្មានលិខិតអនុញ្ញាត ។

40/60

៧-ចាប់ លក់ ទិញ ធ្វើសន្និធិ និងដឹកជញ្ជូនកូន ឬ ពងត្រី និងកូន ឬ ពងវារីសត្វផ្សេងទៀតដោយគ្មានលិខិតអនុញ្ញាត ។

៨-ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍នេសាទឆ្លងឆក់ ។

៩-មិនគោរពតាមផែនការគ្រប់គ្រង និងផែនការប្រមូលផល ផលិតផលជលផលប្រចាំឆ្នាំ ។

ជនណាប្រព្រឹត្តបទល្មើសជលផលចំណុចទី ១ ចំណុចទី ២ ចំណុចទី ៣ ចំណុចទី ៤ ចំណុចទី ៥ និងចំណុចទី ៦ នៅពេលយប់ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ពិន័យក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ហើយវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដងឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ពិន័យក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ហើយវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៩៥.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់សមាមាត្រទៅនឹងថ្លៃឈ្នួលនេសាទ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ផ្ទេរលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទដោយគ្មានការអនុញ្ញាត ។

២-ប្រើប្រាស់នាវានេសាទគ្មានលិខិតអនុញ្ញាតរៀបចំឧបករណ៍នេសាទដែលមានលក្ខណៈត្រៀមធ្វើនេសាទក្នុងដែននេសាទសមុទ្រ ។

៣-ប្រើប្រាស់នាវានេសាទធ្វើនេសាទក្នុងដែននេសាទគ្មានលិខិតអនុញ្ញាត ឬ គ្មានសៀវភៅនាវានេសាទ ។

៤-ប្រើប្រាស់នាវានេសាទមានឧបករណ៍អួនអូសដោយកម្លាំងម៉ាស៊ីននៅក្នុងកន្លែងនេសាទតាមឆ្នេរដោយរៀបចំមានលក្ខណៈត្រៀមធ្វើនេសាទ ។

៥-ប្រើប្រាស់ទូក កាណូត កប៉ាល់នេសាទដោយគ្មានចុះបញ្ជីពីរដ្ឋបាលជលផល ។

41/00

៦-មិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅនាវានេសាទ ។

៧-នេសាទដោយលបលួច ឬ រ៉ាវក្នុងតំបន់កំណត់ហួសសុពលភាពនៃលិខិតអនុញ្ញាត ។

៨-នេសាទជាលក្ខណៈសិប្បកម្មដោយអួនលើសពីបីរយ (៣០០) ម៉ែត្រ នៅក្រៅបឹងទន្លេសាប និងលើសពីប្រាំមួយរយ (៦០០) ម៉ែត្រ នៅក្នុងបឹងទន្លេសាប ។

៩-នេសាទជាលក្ខណៈសិប្បកម្មដោយអួននៅក្នុងកន្លែងនេសាទដែលទុកសម្រាប់តែប្រជាពលរដ្ឋនៅក្នុងកន្លែងដែលធ្វើឱ្យរំខានដល់ការធ្វើអាជីវកម្មក្នុងឡូត៍នេសាទ និងនៅក្នុងកន្លែងនេសាទដែលទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ ។

១០-នេសាទជាលក្ខណៈសិប្បកម្មគ្មានលិខិតអនុញ្ញាត ខុសទីតាំងនេសាទ ខុសយថាប្រភេទឧបករណ៍នេសាទ ឬ ប្រើប្រាស់លិខិតអនុញ្ញាតហួសសុពលភាព ។

១១-នេសាទដោយលបលួច ឬ រ៉ាវ ខុសពេលកំណត់លើសពីប្រាំរយ (៥០០) ម៉ែត្រ រាំងស្ទះដល់ផ្លូវជលយានគ្រប់ប្រភេទ មិនដកចេញតាមពេលកំណត់ក្នុងតំបន់កំណត់ ។

១២-នេសាទជាលក្ខណៈឧស្សាហកម្មដោយគ្មានលិខិតអនុញ្ញាត ឬ ហួសសុពលភាពនៃលិខិតអនុញ្ញាត ។

១៣-នេសាទប៉ះពាល់ ឬ ខូចខាតដល់ស្មៅសមុទ្រ ឬ ផ្កាថ្ម ។

១៤-មិនព្រមផ្អាកការធ្វើនេសាទតាមការបញ្ជប់បណ្តោះអាសន្នរបស់រដ្ឋបាលជលផលមានសមត្ថកិច្ច ។

១៥-ប្រើសាច់មង អួន ឬ លួសសំណាញ់ដែលមានក្រឡាតូចជាងបួន (៤) សង្ទីម៉ែត្រធ្វើរបាំងរួមផ្សំ ឬ ជំនួសរបាំងព្រួល ។

១៦-ធ្វើអាជីវកម្មនេសាទដោយមិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុកឡូត៍នេសាទ ឬ លិខិតអនុញ្ញាតឱ្យធ្វើនេសាទ ។

១៧-បោះរបាំងក្នុងឡូត៍នេសាទ ឬ ផ្លូវទឹកនៃតំបន់ឆ្នេរសមុទ្រដោយមិនបើកមុខទឹកឱ្យជលយានធ្វើចរាចរណ៍បាន ។

១៨-ធ្វើឱ្យចាល់ទឹកនៅមុខរបាំង ។

១៩-បោះទីតាំងឡូត៍ដាយខុសពីការកំណត់ ។

២០-ប្រើឧបករណ៍នេសាទ ឬ ពេលវេលានេសាទនៅក្នុងកន្លែងនេសាទសហគមន៍

៤២៦០

ខុសពីការកំណត់របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ និងវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៩៦.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផល ជាប្រាក់ពីប្រាំលាន(៥.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០) រៀល ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោមៈ

១-ប្រើប្រាស់លិខិតអនុញ្ញាតបង្កើតផែត្រី ទីតាំងកែច្នៃផល ផលិតផលជលផលតាមទ្រង់ទ្រាយឧស្សាហកម្ម ហួសសុពលភាពនៃលិខិតអនុញ្ញាត ។

២-ប្រើប្រាស់នាវានេសាទបរទេសដែលមានលិខិតអនុញ្ញាតឱ្យធ្វើនេសាទចូលចតក្នុងដែននេសាទសមុទ្រកម្ពុជាពុំផ្តល់ព័ត៌មាន ឬ ពុំទាន់មានការអនុញ្ញាតពីរដ្ឋបាលជលផល ។

៣-បានទទួលសិទ្ធិធ្វើអាជីវកម្មឡូត៍នេសាទ មិនបានបំពេញកាតព្វកិច្ចរក្សាការការពារព្រៃលិចទឹក និងទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងនាទីឡូត៍នេសាទ ។

៤-គាស់ កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដែននេសាទដោយគ្មានការអនុញ្ញាត ។

៥-ធ្វើនេសាទក្នុងកន្លែងនេសាទបម្រុងដោយប្រើឧបករណ៍គ្រប់ប្រភេទរួមផ្សំដោយរបាំងព្រួលដែលមានបណ្តោយលើសពីហាសិប (៥០) ម៉ែត្រ ឬ លាតសន្ធឹងលើសពីពីរភាគបី (២/៣) នៃទទឹងមុខទឹក ឬ ធ្វើឱ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទ ។

៦-សិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ឬ យកគំរូពិសោធន៍នៅក្នុងដែននេសាទគ្មានការអនុញ្ញាត ។

៧-ប្រមូលផល ធ្វើសន្និធិផ្កាថ្ម ឬ ចូលចតនាវា បោះយុថ្កានៅក្នុងតំបន់ផ្កាថ្មដោយគ្មានការអនុញ្ញាត ។

៨-បង្កើតផែត្រី ទីតាំងកែច្នៃផល ផលិតផលជលផលតាមទ្រង់ទ្រាយឧស្សាហកម្ម

45/60

គ្មានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ ។

**មាត្រា ៩៥.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីប្រាំរយពាន់ (៥០០.០០០) រៀល ទៅប្រាំលាន (៥.០០០.០០០) រៀល ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

១-មិនរុះរើ និងដកចេញទីតាំងនេសាទក្នុងឡូត៍នេសាទតាមកាលកំណត់ក្នុងច្បាប់នេះ ។

២-បង្កើតទីតាំងទិញ លក់ សន្និធិ ឬ កន្លែងកែច្នៃផល ផលិតផលជលផលតាមទ្រង់ទ្រាយសិប្បកម្មគ្មានលិខិតអនុញ្ញាត ឬ ហួសសុពលភាពនៃលិខិតអនុញ្ញាត ។

៣-ពុំមានសៀវភៅកត់ត្រាស្ថិតិផល ផលិតផលជលផល ។

៤-ពុំបានកត់ត្រាស្ថិតិផល ផលិតផលជលផល ឬ រាយការណ៍ជូនរដ្ឋបាលជលផលឱ្យបានទៀងទាត់ ។

៥-ធ្វើវារីវប្បកម្មគ្រប់ប្រភេទមិនរក្សាគុណភាពដី ទឹក វារីជីវសាស្ត្រ និង បរិស្ថាន ដោយបង្ហូរកាកសំណល់ចូលទៅក្នុងដែននេសាទ ។

៦-តាំងទីលំនៅថ្មីដែលស្ថិតនៅតិចជាងពីរ (២) គីឡូម៉ែត្រ ពីកន្លែងអភិរក្សជលផល ។

៧-នាំចូលពូជវារីសត្វ ឬ វារីរុក្ខជាតិគ្រប់ប្រភេទគ្មានលិខិតអនុញ្ញាត ។

៨-ធ្វើនាវាចរណ៍ឆ្លងកាត់ ឬ ធ្វើសកម្មភាពផ្សេងៗទៀតក្នុងកន្លែងអភិរក្សជលផល ។

៩-ធ្វើអាជីវកម្មផ្សេងៗដែលប៉ះពាល់ ឬ ខូចខាតដល់ស្មៅសមុទ្រ ឬ ផ្កាថ្ម ។

1160 k

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២)ដង ឡើងទៅត្រូវទទួលការពិន័យអន្តរការណ៍ពីរដងនៃចាលផលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ ។

**មាត្រា ៩៨.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ១ ដែលត្រូវដាក់ពន្ធនាគារពីបី(៣) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងវត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល និងដកហូតកិច្ចព្រមព្រៀង ឬ លិខិតអនុញ្ញាត ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក និងព្រៃកោងកាង ឬ ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃលិចទឹក និងព្រៃកោងកាង ។

២-បង្កឱ្យភ្លើងឆេះ ឬ ដុតព្រៃលិចទឹក និងព្រៃកោងកាង ។

៣-ចាក់ចោល បោះចោល បង្ហូរ បាចពង្រាយសារធាតុពុល ឬ ប្រព្រឹត្តសកម្មភាពធ្វើឱ្យពុល ឬ បង្កគ្រោះថ្នាក់ដល់រុក្ខជាតិ និងរុក្ខជាតិនៅក្នុងដែននេសាទ ។

៤-នេសាទដោយឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទនៅក្នុងដែននេសាទ ។

៥-នេសាទដោយឧបករណ៍បូម បាច ពង្រីងផ្នែកណាមួយនៃដែននេសាទ ដែលបង្កឱ្យមានអន្តរាយដល់ធនធានជលផល ។

៦-នេសាទដោយឧបករណ៍ទំនើប ឬ ឧបករណ៍នេសាទដែលបង្កើតថ្មី ឬ របៀបនេសាទបែបថ្មី ឬ ឧបករណ៍នេសាទ ដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលនាំមកនូវការបំផ្លាញមច្ឆជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ។

៧-នេសាទជាលក្ខណៈឧស្សាហកម្មក្នុងរដូវបិទនេសាទ ។

៨-នេសាទជាលក្ខណៈឧស្សាហកម្មក្នុងកន្លែងអភិរក្សជលផល ។

៩-ធ្វើទំនប់កាត់ ឬ លុបទន្លេ ស្ទឹង ព្រែក អូរ បឹង ត្រពាំង ប្រឡាយ អាងទឹក និង

អាងធម្មជាតិ ដែលអាចបង្កមហន្តរាយដល់ធនធានជលផលដោយគ្មានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

១០-បំផ្លាញស្មៅសមុទ្រ ឬ ផ្កាថ្ម និងធ្វើឱ្យអន្តរាយដល់អេកូឡូស៊ី ស្មៅសមុទ្រ ឬ ផ្កាថ្ម ។

១១-សាងសង់ឡ រោងសិប្បកម្ម មូលដ្ឋានកែច្នៃ និងរោងចក្រគ្រប់ប្រភេទដែលប្រើប្រាស់វត្ថុធាតុដើមជាប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាង ។

១២-បំផ្លិចបំផ្លាញ ឬ ធ្វើឱ្យខូចខាតអន្លង់ជ្រៅៗដែលជាជម្រក ឬ កន្លែងពងកូនរបស់វារីសត្វ ។

ជនណាប្រព្រឹត្តបទល្មើសជលផលចំណុចទី ៤ ចំណុចទី ៥ ចំណុចទី ៦ ចំណុចទី ៧ និងចំណុចទី ៨ នៅពេលយប់ ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសជលផលថ្នាក់ទី ១ នៃមាត្រានេះ ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ១ ចាប់ពីពីរ(២)ដង ឡើងទៅ ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសជលផលថ្នាក់ទី ១ នៃមាត្រានេះ ។

**មាត្រា ៩៩.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ២ ដែលត្រូវដាក់ពន្ធនាគារពីមួយ(១)ឆ្នាំ ទៅបី(៣)ឆ្នាំ និងពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅហាសិបលាន (៥០.០០០.០០០) រៀល និងវត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោលចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-បំផ្លាញ លាក់បាំង លក់ ឬ លួចវត្ថុតាងបទល្មើសជលផល ។

២-ផ្លាស់ប្តូរ រំកិល ឬ ជីកកប់បង្គោលព្រំប្រទល់នៃតំបន់គ្រប់គ្រងជលផល ។

៣-ធ្វើឱ្យខូចខាត ឬ បំផ្លាញចោលទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងដែននេសាទ ។

៤-នេសាទជាលក្ខណៈសិប្បកម្មក្នុងកន្លែងអភិរក្សជលផល ។

៥-នេសាទដោយអួនអូសទឹកសាប និងឈិបយន្ត ។

៦-ជីកប្រឡាយ រណ្តៅ ឬ ស្រះទ្រង់ទ្រាយធំ ឬ សាងសង់សំណង់ថ្មីនានា ឬ បូមទឹក

ដែលអាចបង្កមហន្តរាយដល់ធនធានជលផលដោយគ្មានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧-ប្រើឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ សម្រាប់នេសាទជាលក្ខណៈសិប្បកម្ម ឬ ឧស្សាហកម្ម ។

៨-សកម្មភាពដទៃទៀតនៅក្នុងដែននេសាទដែលបង្កអន្តរាយដល់ប្រភពធនធានជលផល ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ២ ចំណុចទី ៤ និងចំណុចទី ៥ នៅពេលយប់ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ១ នៃច្បាប់នេះ ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ២នៃមាត្រានេះចាប់ពីពីរ (២) ដងឡើងទៅត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ១នៃច្បាប់នេះ ។

## មាត្រា ១០០.-

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ២ ដែលត្រូវដាក់ពន្ធនាគារពីមួយ(១) ឆ្នាំ ទៅបី (៣) ឆ្នាំ និង/ឬ ពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅហាសិបលាន (៥០.០០០.០០០) រៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ប្រើខ្សែចងគ្រប់ប្រភេទនិងមធ្យោបាយផ្សេងទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល។

២-នេសាទដោយប្រើទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទដែលបង្កមហន្តរាយដល់ធនធានជលផល ។

៣-នេសាទដោយលបលួច ឬ វ៉ាវក្រៅតំបន់កំណត់ ។

៤-ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឬ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ។

៥-ដាំឈូកក្នុងឡូត៍នេសាទ ។

៦-ដាក់សម្រាស់ ឬ មធ្យោបាយផ្សេងទៀតធ្វើឱ្យត្រី ឬ វារីសត្វកុំ ។

៧-លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឬ ផ្ទេរកន្លែងនេសាទសហគមន៍ ។

4

47100

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ២ នៃមាត្រានេះចាប់ពីពីរ (២) ដងឡើងទៅ ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ១ នៃច្បាប់នេះ ។

**មាត្រា ១០១.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ៣ ដែលត្រូវដាក់ពន្ធនាគារពីមួយ(១) ខែ ទៅមួយ (១) ឆ្នាំ ឬ ពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ទៅប្រាំលាន (៥.០០០.០០០) រៀល វត្ថុតាងទាំងអស់អាចត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-កាប់បំផ្លាញផ្តួលរំលំដើមឈើព្រៃលិចទឹក និងព្រៃកោងកាង ឬ គាស់រំលើងប្រមូលគល់ឈើព្រៃលិចទឹក និងព្រៃកោងកាង ។

២-ពង្រីកផ្ទៃដីកសិកម្ម ឬ ប្រើប្រាស់ដីក្នុងបំណងផ្សេងៗក្រៅពីកិច្ចអភិវឌ្ឍន៍វិស័យជលផលនៅក្នុងតំបន់លិចទឹកដែលត្រូវការពារ ។

៣-ពង្រីកផ្ទៃដីស្រែចំការ ឬ ស្រែអំបិលក្នុងដែននេសាទដោយគ្មានការអនុញ្ញាត ។

៤-ស្ថាបនាផ្លូវសាធារណៈ ដាក់តាំងមូលដ្ឋានសំណង់ ឬ លំនៅដ្ឋានគ្រប់ប្រភេទនៅក្នុងដែននេសាទ ។

៥-ដាំឈូកជាលក្ខណៈអាជីវកម្ម ឬ ពាណិជ្ជកម្មក្នុងតំបន់គ្រប់គ្រងជលផល ។

៦-ដឹកជញ្ជូនសម្រាស់ ។

៧-ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍នេសាទឈិបយន្ត ឬ អួនអូសទឹកសាប ។

៨-នេសាទជាលក្ខណៈសិប្បកម្មក្នុងរដូវបិទនេសាទ ។

៩-នេសាទជាលក្ខណៈគ្រួសារក្នុងកន្លែងអភិរក្សជលផល ។

១០-នេសាទដោយប្រើច្បូក សាង ស្ន ឬឧបករណ៍បាញ់ព្រួញដែលរួមផ្សំកែវភ្នែ ។

១១-នេសាទដោយមងបោះ មងកាំង ឬ មងពស់ថ្នាន់គ្រប់ប្រភេទ ។

១២-នេសាទដោយប្រើមង ឬ អួនគ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង់ទីម៉ែត្រកន្លះ (១,៥ ស.ម) ក្នុងដែននេសាទទឹកសាប ។

១៣-នេសាទដោយមងគ្រប់ប្រភេទដែលមានក្រឡាធំជាងដប់ប្រាំ (១៥) សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ។

១៤-នេសាទដោយប្រើព្រួលគ្រប់ប្រភេទដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាងមួយសង្ទីម៉ែត្រកន្លះ(១,៥ ស.ម) ។

១៥-ទិញ លក់ កែច្នៃ ធ្វើសន្និធិ និងដឹកជញ្ជូនផល ផលិតផលជលផល ដែលបានមកពីការធ្វើនេសាទខុសច្បាប់ ឬ ដោយប្រើឧបករណ៍នេសាទខុសច្បាប់ ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ៣ ចំណុចទី ៨ ចំណុចទី ៩ ចំណុចទី ១០ ចំណុចទី ១១ ចំណុចទី ១២ និងចំណុចទី ១៣ នៅពេលយប់ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ២ នៃមាត្រា ៩៩ នៃច្បាប់នេះ ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ៣ ចាប់ពីពីរ (២) ដងឡើងទៅ ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ២ នៃមាត្រា ៩៩ នៃច្បាប់នេះ ។

**មាត្រា ១០២.-**

សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬ មន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ ឬ ដោយប្រយោលជួយដល់អាជីវកម្មជលផល និងធ្វើសកម្មភាពគ្រប់បែបយ៉ាងផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលជលផល ឬ រាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលជលផល ត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅបី (៣) ឆ្នាំ និង/ឬ ពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀល ទៅហាសិបលាន (៥០.០០០.០០០) រៀល ។

**មាត្រា ១០៣.-**

ចំពោះសកម្មភាពដូចខាងក្រោមដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលជលផល ត្រូវចាត់ទុកជាបទល្មើស និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅបី (៣) ឆ្នាំ និង/ឬ ពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅហាសិបលាន (៥០.០០០.០០០)រៀល :

១-ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២-ចូលរួមទាំងស្រុង ឬ ដោយផ្នែក និងដោយផ្ទាល់ ឬ ដោយប្រយោល ក្នុង

សកម្មភាពណាមួយនៃអាជីវកម្មជលផលដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

៣-អនុគ្រោះចំពោះបទល្មើសជលផលថ្នាក់ទី ១ ។

៤-ប្រកបរបរអាជីវកម្មឡូត៍នេសាទ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តីក្នុងអំឡុងពេលស្ថិតនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ។

៥-មិនបានរាយការណ៍ ឬ មិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសជលផលថ្នាក់ទី ១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។

៦-ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬ ផ្តល់ព័ត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសជលផលថ្នាក់ទី ១ ។

**មាត្រា ១០៤.-**

ជនណាដែលប្រព្រឹត្តអំពើក្លែងបន្លំគ្រប់ប្រភេទដែលទាក់ទងនឹងវិស័យជលផលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១៦

## ការអនុវត្តសាលក្រមតុលាការ

**មាត្រា ១០៥.-**

ការអនុវត្តសាលក្រម ឬ សាលដីកាស្ថាពរនៃបទល្មើសជលផល ជាភារកិច្ចរបស់រដ្ឋ-បាលជលផលមានសមត្ថកិច្ច លើកលែងតែទោសដាក់ពន្ធនាគារ ។

**មាត្រា ១០៦.-**

រាល់សម្រេចសាលក្រម ឬ សាលដីកានៃបទល្មើសជលផល ត្រូវចម្លងមួយច្បាប់ជូនរដ្ឋ-បាលជលផលមានសមត្ថកិច្ច ។

**មាត្រា ១០៧.-**

បន្ទាប់ពីសាលក្រម ឬ សាលដីកាចូលជាស្ថាពរ វត្ថុតាងដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល ត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលជលផល ។

៛

៥០/៦០

## ជំពូកទី ១៧

## អវសានប្បញ្ញត្តិ

**មាត្រា ១០៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០៩.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០០៦

នស/រកម.០៦០៥.២៤៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ**

**ហត្ថលេខា**

**ចាន់ សារុន**

លេខៈ២២៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

## ឧបសម្ព័ន្ធ

**កន្លែងនេសាទបម្រុង** : សំដៅដល់ផ្នែកមួយនៃដែននេសាទទឹកសាបដែលមិនមែនជាឡូតិ៍នេសាទ កន្លែងអភិរក្សជលផល នាទីព្រៃលិចទឹក កន្លែងនេសាទគ្រួសារ ឬទំនាបលិចទឹកក្នុងរដូវជំនោរឡើង។ កន្លែងនេសាទបម្រុងមិនត្រូវបានធ្វើការចាត់ថ្នាក់ជាតំបន់គ្រប់គ្រងជលផលជាក់លាក់ឡើយ ហើយត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទបានតែការនេសាទ ២ប្រភេទ គឺការនេសាទជាលក្ខណៈគ្រួសារ និងការនេសាទជាលក្ខណៈសិប្បកម្ម ។ កន្លែងនេសាទបម្រុងមានជាអាទិ៍ ទន្លេ ស្ទឹង ព្រែក បឹង អាងធម្មជាតិ ឬ ត្រពាំង ។ល។

**កន្លែងនេសាទសហគមន៍** : សំដៅដល់ដែននេសាទរបស់រដ្ឋដែលបានប្រគល់ជូនសហគមន៍ក្រោមកិច្ចព្រមព្រៀងរវាងនាយខណ្ឌរដ្ឋបាលជលផលជាមួយសហគមន៍ ឬក្រុមប្រជាពលរដ្ឋរស់នៅក្នុង ឬ ក្បែរដែននេសាទដែលពឹងផ្អែកលើការធ្វើនេសាទសម្រាប់ការចិញ្ចឹមជីវិត និងការប្រើប្រាស់ជាប្រពៃណី ហើយដែលធ្វើការគ្រប់គ្រង ឬ ប្រើប្រាស់កន្លែងនេសាទនោះប្រកបដោយនិរន្តរភាព ។

**កន្លែងអភិរក្សជលផល** : សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាប ឬ សមុទ្រ ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់សម្រាប់វារីសត្វ ឬ រុក្ខជាតិជ្រកពួនពងកូន រីកធំធាត់ ឬរីកលូតលាស់ ។ កន្លែងអភិរក្សជលផលជាថ្នាលពូជ និងជាតំបន់ការពារធនធានជលផលដែលពុំអាចអនុញ្ញាតឱ្យប្រព្រឹត្តសកម្មភាពដែលនាំឱ្យមានផលប៉ះពាល់ដល់ធនធានជលផលបានឡើយ ក្រៅពីការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផលស្របតាមគោលការណ៍ដ៏ត្រឹមត្រូវ ។

**ការកែច្នៃត្រាមទ្រង់**
**ទ្រាយសិប្បកម្ម** : សំដៅដល់ការកែច្នៃទ្រង់ទ្រាយមធ្យមជាលក្ខណៈបាត្តកម្មដែលមានផល ផលិតផលជលផលចាប់ពីមួយ (១) តោនឡើងទៅ ក្នុងមួយ

(១)ឆ្នាំ ហើយប្រើកម្លាំងពលកម្មច្រើននាក់ដោយពុំមានការបែងចែកក្រុមពលកម្មដាច់ដោយឡែកច្បាស់លាស់ទេ ។

**ការកែច្នៃតាមទ្រង់ទ្រាយខ្នាតមធ្យម** : សំដៅដល់ការកែច្នៃទ្រង់ទ្រាយធំដែលប្រើកម្លាំងពលកម្មច្រើនក្រុមដាច់ដោយឡែកពីគ្នាទៅតាមខ្សែបណ្តាញផលិតកម្មផ្សេងៗគ្នា ។

**ការដឹកជញ្ជូនផល ផលិតផលជលផល ជាលក្ខណៈពាណិជ្ជកម្ម** : សំដៅដល់ការដឹកជញ្ជូនផល ផលិតផលជលផល :

ក) នៅក្នុងប្រទេស :

- ក្នុងរយៈពេលបើកនេសាទនូវផលជលផលទឹកសាបរស់ ឬស្រស់លើសពីពីររយ (២០០) គីឡូក្រាម ឬ ផលិតផលជលផលលើសពីហុកសិប (៦០) គីឡូក្រាម
- ក្នុងរយៈពេលបិទនេសាទនូវផលជលផលទឹកសាបរស់ ឬ ស្រស់លើសពីហុកសិប (៦០) គីឡូក្រាម ឬ ផលិតផលជលផលលើសពីម្ភៃ (២០) គីឡូក្រាម
- ផលជលផលសមុទ្ររស់ឬស្រស់លើសពីពីររយ(២០០)គីឡូក្រាម ឬផលិតផលជលផលលើសពីហុកសិប(៦០)គីឡូក្រាម ។

ខ) ដើម្បីនាំចេញ :

- គ្រប់ការនាំចេញផលជលផលរស់ ឬ ស្រស់ទោះបរិមាណតិចក្តី និងសំដៅដល់ផលិតផលជលផលលើសពីដប់ (១០) គីឡូក្រាម ។

គ) ដើម្បីនាំចូល :

- គ្រប់ការនាំចូលផលជលផលរស់ ឬ ស្រស់ ទោះបរិមាណតិចក្តី និងសំដៅដល់ផលិតផលជលផលលើសពីដប់ (១០) គីឡូក្រាម ។

**ការបង្កកំណើត** : សំដៅដល់ការរលាយចូលគ្នានៃកាម៉ែតញីនិងកាម៉ែតឈ្មោលបង្កើតបានជាស៊ីកូតមួយ ។

**ការពិន័យអន្តរការណ៍** : សំដៅដល់ការពិន័យដោយរដ្ឋបាលជលផលហើយអាចធ្វើបានតែក្នុងករណីជនល្មើសបានយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៨៧ នៃច្បាប់នេះដោយមិនឆ្លងកាត់ស្ថាប័នតុលាការ ។

**ការនេសាទ** : សំដៅដល់ការប៉ុនប៉ង ការស្រាវជ្រាវ ការធ្វើសកម្មភាពដោយប្រើមធ្យោបាយនានា ដើម្បីទាក់ទាញ ចាប់ ដាក់អន្ទាក់ ធ្វើឱ្យរបួសធ្វើឱ្យងីងើ សម្លាប់ និងប្រមូលយកវារីសត្វពីក្នុងដែននេសាទ ។

**ការនេសាទជាលក្ខណៈគ្រួសារ** : សំដៅដល់ការនេសាទទ្រង់ទ្រាយតូចដែលប្រើប្រាស់ឧបករណ៍មានលក្ខណៈទោល ។
ការនេសាទជាលក្ខណៈគ្រួសារក៏ជាការនេសាទដែលមានលក្ខណៈជាប្រពៃណីហើយជាទូទៅពុំមែនសម្រាប់គោលបំណងធ្វើពាណិជ្ជកម្មទេ ។

**ការនេសាទជាលក្ខណៈសិប្បកម្ម** : សំដៅដល់ការនេសាទទ្រង់ទ្រាយមធ្យមប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈទោល ឬ ឧបករណ៍នេសាទមានលក្ខណៈជាបរិក្ខារហើយធ្វើសកម្មភាពនេសាទដោយកម្លាំងពលកម្មម្នាក់ ឬ ច្រើននាក់ ។ ក៏ប៉ុន្តែក្នុងការធ្វើនេសាទដោយកម្លាំងពលកម្មច្រើននាក់ ក៏ដោយ ក៏សកម្មភាពនោះមិនអាចបែងចែកក្រុមដោយឡែកពីគ្នាច្បាស់លាស់ឡើយហើយថែមទាំងអនុវត្តសកម្មភាពក្នុងពេលព្រមគ្នា ។

**ការនេសាទជាលក្ខណៈឧស្សាហកម្ម** : សំដៅដល់ការនេសាទទ្រង់ទ្រាយធំដែលប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈជាបរិក្ខារហើយធ្វើសកម្មភាពនេសាទដោយប្រើប្រាស់កម្លាំងពលកម្មតាមក្រុមដាច់ដោយឡែកពីគ្នាហើយក្រុមនីមួយៗអាចប្រើពេលវេលាពលកម្មខុសគ្នា ។

**កែច្នៃផលនេសាទ** : សំដៅដល់ការដាក់បញ្ចូលផលនេសាទទៅក្នុងដំណើរការឧស្សាហកម្ម ឬ ផលិតកម្មទ្រង់ទ្រាយតូច ឬ ធំ ក្នុងគោលបំណងប្រែក្លាយលក្ខណៈដើមរបស់វា ឬ រក្សាទុកវាជាដើមដោយពុំរាប់បញ្ចូលនូវការកែច្នៃផលនេសាទទាំងឡាយដោយរោងចក្រធុនតូច ធំ មធ្យម សិប្បកម្ម ដែលបានធ្វើការវេចខ្ចប់ច្រកចូលក្នុងកំប៉ុង ឬ កែវ ដបបិទជិត ឬ មានសំបកវេចខ្ចប់បិទជិតដែលការពារបាននូវការចម្លងមេរោគផ្សេងៗ ។

**ជម្រក** : សំដៅដល់ទីកន្លែងសម្រាប់ជ្រកមួយផងមួយកាល ឬ អចិន្ត្រៃយ៍របស់មច្ឆជាតិ និងវារីសត្វ ទោះបីតំបន់ទឹកសាប ឬ សមុទ្រ ។ ទីជម្រកទាំងនោះរួមមាន : កន្លែងអភិរក្សជលផល អន្លង់ជ្រៅៗ តំបន់ព្រៃលិចទឹក តំបន់ផ្កាថ្ម តំបន់ស្មៅសមុទ្រ បឹងទន្លេសាប ស្រះ ឬ អន្លង់ជ្រៅៗនៅតាមវត្ត តំបន់ការពារធម្មជាតិ និងកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍ ។

**ជលផល** : សំដៅដល់ឯកតានៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬ សិប្បនិម្មិត ក្រោមទម្រង់ជាដីលិចទឹកដែលគ្របដណ្តប់ទៅដោយទឹកអចិន្ត្រៃយ៍ ឬ ជំនើង ឬ ទឹកជោរ នាច និងរុក្ខជាតិចម្រុះលិចទឹកព្រមទាំងធនធានជីវសាស្ត្រដូចជាវារីសត្វរួមទាំងផ្កាថ្ម វារីរុក្ខជាតិដែលបង្កកំណើតនៅក្នុងទឹក ។

**ជលយាន** : សំដៅដល់ឧបករណ៍អណ្តែតទឹកដែលប្រើប្រាស់សម្រាប់ផ្ទុក ឬ ជាមធ្យោបាយ មានជាអាទិ៍ ទូក កាណូត កប៉ាល់ សំពៅ សាំប៉ាន ឬ ក្បូន ។

**តំបន់ទឹកជំនោរ** : សំដៅដល់កន្លែងដែលមានថ្មរកេតរកូតនៅទន្លេមេគង្គ លើកាំពីពីខេត្តក្រចេះទៅព្រំប្រទល់ប្រទេសឡាវដែលមានអន្លង់ជ្រៅៗដែលបំបែងចរន្តទឹកឱ្យលឿន រួមទាំងរុក្ខជាតិលិចទឹក ដូចជាព្រៃអញ្ចែងជាដើមដែលជាជម្រក និងជាកន្លែងពងកូននៃមេត្រីពូជ ។

**ទំនាបលិចទឹកនៅ**
**រដូវដំឡើង** : សំដៅដល់ដីទំនាបទទួលរបបទឹកទន្លេមេគង្គដែលមិនមែនជាទីតាំងឡូត៍នេសាទ ព្រៃលិចទឹក កន្លែងអភិរក្សជលផល កន្លែងនេសាទគ្រួសារ និងកន្លែងនេសាទបម្រុង រួមមាន វាលទំនាប វាលស្មៅ វាលស្រែចំការ និងដីដែលទឹកទន្លេមេគង្គឡើងដល់ ហើយដែលជាទីវាលទំនាបដ៏សំខាន់សម្រាប់មច្ឆជាតិធ្វើចរាចរណ៍រកកន្លែងពងកូននិងស្វែងរកចំណីនៅក្នុងរដូវបិទនេសាទ ។

**ទ្រព្យសម្បត្តិរបស់រដ្ឋនៅ**
**ក្នុងដែននេសាទ** : សំដៅដល់ទ្រព្យសម្បត្តិសាធារណៈនិងឯកជនរបស់រដ្ឋនៅក្នុងដែននេសាទ ដូចជា ការិយាល័យ ស្នាក់ការ មធ្យោបាយធ្វើដំណើរ ដឹកជញ្ជូន និងប្រើប្រាស់របស់មន្ត្រីរដ្ឋបាលជលផលសម្រាប់អនុវត្តច្បាប់ បង្គោល ឬ ពោងព្រំប្រទល់តំបន់គ្រប់គ្រងជលផលជាដើម ។

**ធនធានជលផល** : សំដៅដល់អត្ថន័យដូចមានចែងក្នុងមាត្រា៤នៃច្បាប់នេះហើយដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញនិងនេសាទ ។

**នាទីព្រៃលិចទឹក**
**និងព្រៃកោងកាង** : សំដៅដល់ផ្ទៃដីលិចទឹកដោយរបបទឹកទន្លេមេគង្គ ឬ ដីលិចទឹកដោយរបបទឹកជោរ នាច របស់សមុទ្រដែលគ្របដណ្តប់ដោយព្រៃលិចទឹក និងព្រៃកោងកាង ។ នាទីព្រៃលិចទឹកនិងព្រៃកោងកាងរាប់បញ្ចូលទាំងតំបន់លិចទឹកដែលត្រូវការពារ ។

**នាវានេសាទ** : សំដៅដល់ជលយានគ្រប់ប្រភេទដែលគេបំពាក់ឧបករណ៍នេសាទសម្រាប់នេសាទ ។

**ផលនេសាទកែច្នៃ** : សំដៅដល់ផលនេសាទដែលបានឆ្លងកាត់ការកែច្នៃរួចហើយ ។

**ផល ផលិតផល**

**ជលផល** : សំដៅដល់ផលដែលគេរុករក និងប្រមូលយកវាពីធម្មជាតិ មានវារីសត្វ និងវារីរុក្ខជាតិ ដូចជាមច្ឆជាតិ ផ្កាថ្ម សារាយជាដើម ដែលអាចហៅបានថាជាផលជលផល ។ ពេលដែលគេយកផលរុករកប្រមូលយកបានពីធម្មជាតិទៅកែច្នៃ គេនឹងទទួលបានផលិតផលកែច្នៃផលជលផល(ផលិតផលជលផល)ដែលមានជាអាទិ៍ផលនេសាទកែច្នៃ(ប្រហុក ផ្អក ត្រីឆ្អើរ ត្រីងៀត បង្គាក្រៀម ។ល។) ឬ សារាយក្រៀមជាដើម ។ ផលិតផលកែច្នៃផលជលផលទាំងនេះពុំបានរាប់បញ្ចូលនូវផលិតផលទាំងឡាយណាដោយរោងចក្រធុនតូច ធំ មធ្យម សិប្បកម្មដែលបានធ្វើការវេចខ្ចប់ច្រកចូលក្នុងកំប៉ុង ឬ កែវ ដបបិទជិត ឬ មានសំបកវេចខ្ចប់បិទជិតដែលការពារបាននូវការចម្លងមេរោគផ្សេងៗ ។

**ដៃត្រី** : សំដៅដល់ស្តុកត្រី ឬ ហ្វូងត្រីជាដែបណ្តែតនៅជាប់មាត់ទឹក ឬ ជាស្តុកនៅលើគោក ដែលជាកន្លែងប្រមូល ធ្វើសន្និធិ ចែកចាយធ្វើពាណិជ្ជកម្មផល ផលិតផលជលផល ។

**ព្រៃលិចទឹក និង ព្រៃកោងកាង** : សំដៅដល់ឯកតានៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬ សិប្បនិម្មិតក្រោមទម្រង់ជាដីលិចទឹក ដែលគ្របដណ្តប់ដោយរុក្ខជាតិចម្រុះ ទោះបីដុះដោយធម្មជាតិក្តី ឬ ដោយដាំក្តី រួមទាំងធនធានធម្មជាតិដទៃស្ថិតនៅក្នុងនោះ ដែលមានគោលបំណងប្រើប្រាស់សំខាន់ គឺជាជម្រកពង កូនរបស់ត្រី និងវារីសត្វទាំងអស់។ពុំត្រូវចាត់ទុកជាព្រៃលិចទឹកនិងព្រៃកោងកាង រួមមាន ដំណាំកសិកម្ម ឬ ដំណាំឧស្សាហកម្មនិងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

**វារីរុក្ខជាតិ** : សំដៅដល់រុក្ខជាតិទឹកតូចៗដែលកកើត ឬ ដុះ និងរីកលូតលាស់នៅក្នុងទឹក ព្រមទាំងហ្វីតូប្លង់តុងដោយប្រភេទខ្លះកកើត និងរីកលូតលាស់នៅស្រទាប់បាត ប្រភេទខ្លះដុះនិងរីកលូតលាស់បណ្តែតទឹក

ប្រភេទខ្លះកកើត ឬដុះនៅស្រែទាប់បាត និងរីកលូតលាស់ស្លឹកដើមទង មែកនៅលើទឹកហើយប្រភេទខ្លះទៀតអាចរស់នៅលើគោកបានមួយរយៈពេលដែលទឹកនឹងរីងហួតអស់ ។

**វារីវប្បកម្ម** : សំដៅដល់ការភ្ញាស់ ការបង្កាត់ ការចិញ្ចឹម ការបំប៉នពងត្រី កូនត្រី ត្រី ឬ វារីសត្វ ឬ ការដាំ ការបណ្តុះពូជវារីរុក្ខជាតិក្នុងគោលបំណងធ្វើឱ្យកើនចំនួនឱ្យរីកលូតលាស់ ឬរីកធំធាត់វារីសត្វ ឬ វារីរុក្ខជាតិ ។

**វារីសត្វ** : សំដៅដល់ពួកសត្វបង្កកំណើតក្នុងទឹក មានជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ ចាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតព្រមទាំងពង កូនរបស់វា ដែលរស់នៅជាសំខាន់ក្នុងទឹក ។ ប្រភេទវារីសត្វត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**វារីសត្វគ្មានជីវិត** : សំដៅដល់សំណាកវារីសត្វ ឬ វារីសត្វដែលស្លាប់ ទោះជានៅខ្លួនទាំងមូល សរីរាង្គក្នុង សរីរាង្គក្រៅ បំណែកឆ្អឹងឬផលិតផលកែច្នៃក៏រាប់បញ្ចូលជាធនធានជលផល ។

**សត្វបង្កកំណើតក្នុងទឹក** : សំដៅដល់សត្វដែលត្រូវការលក្ខខណ្ឌចាំបាច់ក្នុងការបង្កកំណើតក្នុងទឹក រស់នៅអាស្រ័យដោយទឹក នៅក្នុងទឹក ឬ នៅក្បែរទឹក ជាមំសាសី តិណាសី ឬ សព្វាសី ដែលភាគច្រើនចិញ្ចឹមជីវិតដោយចំណីជាសត្វទឹក ឬ រុក្ខជាតិទឹក ។

**សន្និធិ** : សំដៅដល់ការរក្សាទុកមួយរយៈនូវផល ផលិតផលជលផលនៅក្នុងទីតាំងណាមួយក្នុងគោលបំណងលក់ផល ផលិតផលជលផលនោះឱ្យបានទទួលតម្លៃលើសហើយក៏ដើម្បីជៀសវាងការភាន់ច្រឡំរវាងផលរក្សាទុក និងផលដែលចាប់យកពីធម្មជាតិនៅក្នុងរដូវបិទនេសាទ។

**សម្រាស់** : សំដៅដល់គល់ ដើម ឬ មែកឈើ និងវត្ថុផ្សេងៗដែលអ្នកនេសាទយកទៅដាក់នៅក្នុងដែននេសាទទៅតាមទំហំផ្សេងៗដើម្បីបង្កើត

ជាជម្រកទាក់ទាញត្រីឱ្យប្រមូលផ្ដុំនៅមួយកន្លែងរហូតដល់ពេលវេលាមួយសមស្របទើបគេធ្វើនេសាទដោយប្រើឧបករណ៍នេសាទហ៊ុមព័ទ្ធចាប់យកត្រី ។

**សាយតេស** : សំដៅដល់អនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។

**ឡូត៍នេសាទ** : សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាបដែលផ្ដល់នូវផលនេសាទហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់ដែលមានប្រព័ន្ធបឹង ព្រែក ព្រៃលិចទឹក ធនធានជលផល និងជីវចម្រុះ ដែលកំណត់នូវការកកើត និងរីកធំធាត់របស់មច្ឆជាតិ វារីសត្វនិងវារីរុក្ខជាតិហើយនិងត្រូវបានកំណត់នូវទីតាំង និងពេលវេលាអាជីវកម្មជាក់លាក់ដោយមិនជះឥទ្ធិពលដល់ទីតាំងដទៃទៀត ។

**អនុផលព្រៃលិចទឹក និងព្រៃកោងកាង** : សំដៅដល់ផលនៃរុក្ខជាតិមិនមែនឈើព្រៃលិចទឹកនិងព្រៃកោងកាងដែលផ្ដល់ដោយព្រៃលិចទឹក និងព្រៃកោងកាង ។ អនុផលព្រៃលិចទឹក និងព្រៃកោងកាង នឹងកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**អន្លង់ជ្រៅៗ** : សំដៅដល់រណ្ដៅ ឬ អន្លង់ដែលមានជម្រៅជ្រៅ ភាគច្រើនស្ថិតនៅទន្លេមេគង្គលើ ដែលជាជម្រកចាំបាច់សម្រាប់ត្រីមេពូជជ្រក ពូននិងពង កូន បន្តពូជ ។

**ឧបករណ៍ឆក់** : សំដៅដល់ឧបករណ៍នេសាទប្រើចរន្តអគ្គិសនី ឬ ឧបករណ៍បំលែងចរន្តពីភ្លើងអាគុយទៅចរន្តអគ្គិសនី ។

**ឧបករណ៍នេសាទ** : សំដៅដល់បរិក្ខារ ឬ វត្ថុដែលអាចប្រើប្រាស់ក្នុងសកម្មភាពប្រមូលយកវារីសត្វមានជាអាទិ៍ មង អួន សន្ទូច លប អន្ទាក់ ពូ ខ្សែ កំសួលពោងផ្លស់ ឈើ ឬស្សី ម៉ាស៊ីន ភ្លើង នុយ ឬ សារធាតុគីមី ។

**ឧបករណ៍នេសាទ**
**គ្រួសារ** : សំដៅដល់ឧបករណ៍នេសាទដែលគេប្រើប្រាស់សម្រាប់ការនេសាទជាលក្ខណៈគ្រួសារ ។ ឧបករណ៍នេសាទគ្រួសារត្រូវបានបែងចែកដាច់ពីឧបករណ៍នេសាទសិប្បកម្ម ដោយលក្ខណៈសំគាល់តាមទ្រង់ទ្រាយ ទំហំ ចំនួន និងប្រភេទរបស់ឧបករណ៍នោះ ។ ឧបករណ៍នេសាទគ្រួសារនឹងកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ឧបករណ៍នេសាទ**
**សិប្បកម្ម** : សំដៅដល់ឧបករណ៍នេសាទដែលគេប្រើប្រាស់សម្រាប់ការនេសាទជាលក្ខណៈសិប្បកម្ម ។ ចំពោះឧបករណ៍នេសាទមានលក្ខណៈទោលលក្ខណៈសម្គាល់របស់វាយោលទៅតាមទ្រង់ទ្រាយ ទំហំ ប្រភេទនិងចំនួននៃឧបករណ៍នោះ ។ ឧបករណ៍នេសាទសិប្បកម្មនឹងកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ឧបករណ៍នេសាទ**
**ហាមឃាត់** : សំដៅដល់ឧបករណ៍នេសាទដែលបំផ្លិចបំផ្លាញជាខ្លាំង ដល់ប្រភពធនធានជលផល ដែលមានជាអាទិ៍ ឧបករណ៍ឆក់សារធាតុពុលគ្រឿងផ្ទុះ ឧបករណ៍បូមពង្រីង ច្បូក រួមផ្សំកែវផ្ទុះ មងអួនក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ(១,៥ស.ម)ឧបករណ៍នេសាទស្បៃមុងអួនអូសតូ និងអួនហ៊ុមរួមផ្សំភ្លើងជាដើម ។

**ឧបករណ៍នេសាទ**
**ឧស្សាហកម្ម** : សំដៅដល់ឧបករណ៍នេសាទដែលគេប្រើប្រាស់សម្រាប់ការនេសាទជាលក្ខណៈឧស្សាហកម្ម ។ ឧបករណ៍នេសាទឧស្សាហកម្មនឹងកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

4

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ១០៥/០០៥/២០០៦
ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**
លេខ : ០៧៧/០០៤/២០០៦ កបធ.ច
ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៥៤/០៥០៦/ពស/នវ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០០៦ របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ វេលាម៉ោង ១៤ : ១០ នាទី

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌទី២ ឃ្លាទី១ ចែងថា *"បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ"* ។ សំណើរបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា លេខ០៥៤/០៥០៦/ពស/នវ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ វេលាម៉ោង ១៤:១០នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

- យល់ឃើញថា មាត្រា ១០៦ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ បានប្រគល់ឱ្យព្រឹទ្ធសភា (មិនមែនការិយាល័យបណ្តោះអាសន្នទេ) ប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗនិងបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភានិង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល
- យល់ឃើញថា ប្រការ ៥ ចំណុច ខ ដែលចែងថា " *ការិយាល័យបណ្តោះអាសន្នមានភារកិច្ចជ្រើសតាំងប្រធាន និង អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា* " ផ្ទុយនឹងមាត្រា ១០៦ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ ពីព្រោះការិយាល័យបណ្តោះអាសន្នមានសិទ្ធិរៀបចំការបោះឆ្នោតជ្រើសតាំងប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភាតែប៉ុណ្ណោះ ។ ការជ្រើសតាំងប្រធាន និង អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ជាភារកិច្ចរបស់ព្រឹទ្ធសភា
- យល់ឃើញថា ប្រការ ១៩ កថាខណ្ឌទី២ ដែលចែងថា " *ក្នុងករណីពិសេសបន្ទាន់ ដែលមិនអាចបោះឆ្នោតដាច់ដោយឡែកពីគ្នាបាន ការបោះឆ្នោតអាចធ្វើឡើងក្នុងពេលតែមួយ មានទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ បាន ។ សន្លឹកឆ្នោត ត្រូវធ្វើដាច់ដោយឡែកពីគ្នា* " ផ្ទុយនឹងមាត្រា ១០៦ ថ្មី (មួយ) កថាខណ្ឌទី២នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និង ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល* " តែប៉ុណ្ណោះ
- យល់ឃើញថា ប្រការ២០ ដែលចែងថា " *កាលបើជ្រើសរើសប្រធាន និង អនុប្រធានបានហើយ ប្រធានការិយាល័យបណ្តោះអាសន្ន ត្រូវប្រកាសបញ្ចប់ភារកិច្ចរបស់ការិយាល័យបណ្តោះអាសន្ន ហើយប្រគល់ការងារជូនប្រធានព្រឹទ្ធសភាដែលទើបបានជ្រើសតាំង* " ផ្ទុយនឹងមាត្រា ១០៦ ថ្មី (មួយ) កថាខណ្ឌទី២នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និង ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភានិង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល* "
- យល់ឃើញថា ប្រការ ២៥ ផ្ទុយនឹងមាត្រា ១០៦ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ប្រការ ១០៩ កថាខណ្ឌទី២ បានចែងថា " *ក្នុងករណីទុញទាល់ពុំមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះទេ ប្រធានព្រឹទ្ធសភាត្រូវសុំការសម្រេចពីគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ ពី*

*សម័យប្រជុំពេញអង្គអំពីនីតិវិធីសមស្រប ដែលត្រូវយកមកអនុវត្ត*" នោះ មានលក្ខណៈផ្ទុយនឹងមាត្រា១៤០ថ្មី កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញដែលចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ* "

- យល់ឃើញថា នៅក្នុងគ្រប់ជំពូក និង ប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភា ពុំមានបទបញ្ញត្តិណាដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែបទបញ្ញត្តិនៃប្រការ ៥ ចំណុច ខ ប្រការ ១៩ កថាខណ្ឌទី២ ប្រការ ២០ ប្រការ ២៥ និង ប្រការ ១០៩ កថាខណ្ឌទី២ ។

## សម្រេច

**មាត្រា ១.** បទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី ១ នីតិកាលទី២ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៥ ចំណុច ខ ដែលមិនស្របនឹងមាត្រា ១០៦ថ្មី ( មួយ) នៃរដ្ឋធម្មនុញ្ញ ប្រការ ១៩ កថាខណ្ឌទី២ ប្រការ២០ ប្រការ ២៥ មិនស្របនឹងមាត្រា ១០៦ថ្មី ( មួយ) កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ១០៩ កថាខណ្ឌទី២ មិនស្របនឹងមាត្រា១៤០ ថ្មី កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០១ខែមិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :......៥៦......អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៩.២៤៦ លានរៀល (ប្រាំបួនពាន់ពីររយសែសិបប្រាំមួយលានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) ជូនក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទូទាត់បំណុលថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈ និង ឯកសណ្ឋាន ក្នុងឆ្នាំ ២០០៣ ជូនក្រុមហ៊ុន **សូគីម៉ិច** ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:....៥៧..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត "អូនាង"

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញក្រឹត្យក្រុមប្រឹក្សារដ្ឋនៃកម្ពុជាលេខ ៩៧ក្រ. ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- យោងអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ល.ក.

- យោងអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា ៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត "អូនាង"** ( Poipet "O'Neang" SEZ ) ដែលមានទីតាំងស្ថិតនៅឃុំប៉ោយប៉ែត និងឃុំនិមិត្ត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

**មាត្រា ២.-**

**តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត "អូនាង"** មានទំហំ បីរយប៉ែតសិបប្រាំមួយហិកតា និងពីរពាន់ប្រាំបួនរយកៅសិបមួយម៉ែត្រក្រឡា ដូចមានប្លង់ទីតាំង ព្រំប្រទល់ ភូមិសាស្ត្រ ក្នុងឧបសម្ព័ន្ធដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត "អូនាង"** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជន ស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទបញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា ។ ស.ហ.

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបន្ទាយមានជ័យ និងក្រុមហ៊ុនឆាយឆាយអ៊ិនវេសមេន អិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស

**សុខ ចិន្តា**

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៥ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ


តំបន់សេដ្ឋកិច្ចពិសេស "អូរនាង" ប៉ោយប៉ែត
POIPET "O'NEANG" SPECIAL ECONOMIC ZONE
THAILAND
CAMBODIA
KM 10.5 (Thai side)
TA-43015/17444
commercial zone
("wholesale market")
Phum Ang Seila
Seila Khmaer
Ou Neang
dryport
Industrial zone
Poipet airport
Tuol Prasat
Ou Ruessei
Tuol Pongro
Prey Kob
Procheathoam
Paoy Paet
OU CHROV
Kilou Lekh Buon
Souriya
Koun Damrei
Highway
Nimit Thmei
Nimit Mu
TA-47167/07618
ឆាយ ឆាយ អ៊ិនវេសមេន
财财投资发展有限公司
CHHAY CHHAY INVESTMENT LTD
POIPET, SPECIAL ECONOMIC ZONE DEVELOPMENT COMPANY

# ឧបសម្ព័ន្ធ


ប្លង់បង្ហាញទីតាំងតំបន់ពាណិជ្ជកម្ម
ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ
1518100Nm
1517200Nm
242200Em
243200Em
244200Em
GPS001
GSP002
GPS003
GPS004
GPS005
ភ្នំពេញ.ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៤
ប្រធានក្រុមវាស់វែង
មាស ប៊ុនធឿន
បង្គោល GPS
បង្គោលព្រំ
ក្រឡាផ្ទៃ : ៨១.៣៥២៩ ហិកតា
មាត្រដ្ឋាន ១ : ១០០០០

## ឧបសម្ព័ន្ធ

### ប្លង់បន្ទាត់ព្រំតំបន់អភិវឌ្ឍន៍ឧស្សាហកម្មកែច្នៃសំរាប់នាំចេញ
### ឃុំនិមិត្ត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ




ភ្នំពេញ.ថ្ងៃទី ២៤....ខែ..........ឆ្នាំ ២០០៤
ប្រធានក្រុមវាស់វែង

មាស ចិន្ដឿន

# ឧបសម្ព័ន្ធ

## តារាងកូអរដោនេនៃបង្គោលព្រំដី

### តំបន់ឧស្សាហកម្មកែច្នៃសំរាប់នាំចេញ និង តំបន់ពាណិជ្ជកម្ម ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

| តំបន់ឧស្សាហកម្មកែច្នៃសំរាប់នាំចេញ | | |
|---|---|---|
| Code | Northing | Easting |
| A | 1515703.513 | 246220.164 |
| B | 1515795.363 | 248210.790 |
| C | 1515598.046 | 248202.305 |
| D | 1515671.029 | 249246.699 |
| E | 1514787.219 | 249253.460 |
| F | 1514735.451 | 248636.235 |
| G | 1514923.102 | 248633.443 |
| H | 1514904.180 | 248141.186 |
| I | 1515113.219 | 248161.205 |
| J | 1515077.669 | 247262.403 |
| [illegible] | 1514980.925 | 247250.431 |
| L | 1514916.571 | 246229.428 |
| M | 1514635.947 | 248990.961 |
| N | 1514642.611 | 249076.547 |
| O | 1514526.308 | 249066.822 |
| P | 1514382.821 | 249069.376 |
| Q | 1514180.069 | 249071.918 |
| R | 1513882.449 | 248998.651 |
| S | 1513732.963 | 248946.110 |
| T | 1513428.220 | 248817.600 |
| U | 1513427.618 | 248408.351 |
| V | 1513362.610 | 248106.584 |
| W | 1513405.492 | 247710.508 |
| X | 1514589.471 | 247709.111 |
| Y | 1514604.862 | 248118.055 |

| តំបន់ពាណិជ្ជកម្ម | | | | | |
|---|---|---|---|---|---|
| Code | Northing | Easting | Code | Northing | Easting |
| 1 | 1517522.885 | 242255.867 | 26 | 1517830.989 | 243999.892 |
| 2 | 1517738.913 | 242596.793 | 27 | 1517803.880 | 243893.771 |
| 3 | 1517740.176 | 242599.633 | 28 | 1517750.846 | 243919.715 |
| 4 | 1517749.479 | 242784.823 | 29 | 1517695.175 | 243733.289 |
| 5 | 1517748.644 | 243102.452 | 30 | 1517762.977 | 243719.875 |
| 6 | 1517749.260 | 243265.533 | 31 | 1517732.373 | 243634.243 |
| 7 | 1517760.548 | 243291.876 | 32 | 1517713.320 | 243497.550 |
| 8 | 1517853.033 | 243465.748 | 33 | 1517671.982 | 243325.894 |
| 9 | 1517888.066 | 243534.200 | 34 | 1517668.384 | 243314.827 |
| 10 | 1517895.393 | 243546.031 | 35 | 1517631.302 | 243219.940 |
| 11 | 1517908.890 | 243561.317 | 36 | 1517556.684 | 243263.637 |
| 12 | 1518119.346 | 243776.088 | 37 | 1517500.743 | 243211.264 |
| 13 | 1518173.977 | 243826.641 | 38 | 1517446.356 | 243162.384 |
| 14 | 1518268.721 | 243910.994 | 39 | 1517435.119 | 243168.840 |
| 15 | 1518342.615 | 243977.673 | 40 | 1517344.078 | 243091.027 |
| 16 | 1518373.830 | 244007.482 | 41 | 1517268.168 | 243026.010 |
| 17 | 1518401.221 | 244050.078 | 42 | 1517191.843 | 242960.181 |
| 18 | 1518431.120 | 244098.747 | 43 | 1517116.972 | 242894.763 |
| 19 | 1518454.053 | 244135.055 | 44 | 1517185.902 | 242814.435 |
| 20 | 1518491.760 | 244194.734 | 45 | 1517252.007 | 242740.658 |
| 21 | 1518207.248 | 244221.587 | 46 | 1517153.981 | 242605.472 |
| 22 | 1518053.183 | 244239.336 | 47 | 1517122.620 | 242471.970 |
| 23 | 1517808.039 | 244260.547 | 48 | 1517083.713 | 242380.231 |
| 24 | 1517797.843 | 244162.005 | | | |
| 25 | 1517853.356 | 244158.442 | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១:** ត្រូវបានតែងតាំងសមាជិកនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ក.ប.ស) ដូចមានរាយនាមខាងក្រោម:

១.លោក អ៊ឹម ចាន់ថុល ជាសមាជិកផ្នែកផែនការ និងទំនាក់ទំនងសាធារណៈនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយករង

២.លោក អ៊ុង លុយណា ជាសមាជិកផ្នែកស្រាវជ្រាវ និងវិភាគគោលនយោបាយនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៣.លោក ជា ម៉េង ជាសមាជិកផ្នែកផែនការ និងទំនាក់ទំនងសាធារណៈនៃអគ្គលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៤.លោក ទេព ភិយ្យោរិទ្ធ ជាសមាជិកផ្នែកស្រាវជ្រាវ និងវិភាគគោលនយោបាយនៃអគ្គលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៥. លោក ខាន់ វណ្ណៈ ជាសមាជិកផ្នែកផែនការ និងទំនាក់ទំនងសាធារណៈនៃអគ្គលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៦.លោក ល័ស ពិនិត្យ ជាសមាជិកផ្នែកស្រាវជ្រាវ និងវិភាគគោលនយោបាយនៃអគ្គលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល :***
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៨៧៨៥...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម លោកជំទាវ ឧកញ៉ា និងអស់លោក ជាសប្បុរសជន ចំនួន២៧រូប ដែលបានបរិច្ចាគធនធាន ឧបត្ថម្ភដល់មូលនីធិកាកបាទក្រហមកម្ពុជា ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

១-ឯកឧត្តម **ម៉ែន ស៊ីម៉ន**
២-លោកជំទាវ **ម៉ែន គន្ធី**
៣-ឧកញ៉ា **សំ អាង**
៤-លោកជំទាវ **គូ ហុងស៊ួន**
៥-លោកជំទាវ **ហេង សុខា**
៦-ឯកឧត្តម **ភុក អាន**
៧-ឯកឧត្តម **លី យ៉ុងផាត់**
៨-ឯកឧត្តម **សុខ គង់**
៩-ឧកញ៉ា **ខូវ សម្បត្តិ**
១០-ឧកញ៉ា **គិត ម៉េង**
១១-លោកជំទាវ **ជឹង សុភាព**
១២-ឧកញ៉ា **គួ គីមឡុង**

១៣-ឧកញ៉ា ស៊ិន សុខណា
១៤-លោកជំទាវ ម៉ីជីក្ខ ត្តនី
១៥-ឯកឧត្តម លូ គីមឈុន
១៦-លោកជំទាវ ខៀវ ស៊ីណា
១៧-ឯកឧត្តម ចំរុង សារុន
១៨-ឯកឧត្តម ស៊ុយ សែម
១៩-ឧកញ៉ា លឹម ឈីវហួរ
២០-ឧកញ៉ា ហ៊ុន ឈាំងហួរ

**ខ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

១-លោក ឌូ ផន
២-លោក ឆន់ សេខ
៣-លោក ឈាន ឆន
៤-លោក ជូ សាន
៥-លោក ប៊ុន អៀងឡេង

**គ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

១-ឯកឧត្តម ហ៊ី ឈាវី
២-ឯកឧត្តម រស់ វណ្ណា

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៤៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៦៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៥រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ នៅ*វត្តកងចក្រ វត្តសាគរបុរី* និង*វត្តមុនីរៃ* ក្នុងស្រុកកងមាស ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **យូ ស៊ុនឡុង** នៅក្រុងភ្នំពេញ ថវិកា ចំនួន ២៤.៧៨៣.៤១ ដុល្លារ

២-លោកជំទាវ **យិន អ៊ីុយនី** នៅក្រុងភ្នំពេញ ថវិកា ចំនួន ២០.៤៨៥.២៤ ដុល្លារ

៣-លោកជំទាវ **ហួត សុមាលី** នៅក្រុងភ្នំពេញ ថវិកា ចំនួន ១.៩០០ ដុល្លារ និង ៤២.០៧៥.០០០ រៀល

៤-ភិក្ខុ **សាន់ លាងឃីម** នៅខេត្តកំពង់ចាម បច្ច័យ ចំនួន ១០.០៦២ ដុល្លារ

៥-លោក **ខាញ់ សិទ្ធិណារ៉ា** នៅក្រុងភ្នំពេញ ថវិកា ចំនួន ១២.៥០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៧៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៣៧៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនឧកញ៉ា **វិញ** **ឆារ** ប្រធានក្រុមហ៊ុន *កំពតស្មែសសល អេក្សព៉ូ មិក ហ្សូន ខូអិលធីឌី* ដែលបានឧបត្ថម្ភនូវទឹកប្រាក់ ចំនួន ៧០.០០០ ដុល្លារ ជូនដល់សម្តេចនាយករដ្ឋមន្ត្រី ដើម្បីប្រើប្រាស់ក្នុងការដោះស្រាយកិច្ចការទាំងឡាយដែលចាំបាច់ចំពោះមុខ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ :..៣៧៨..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំង លោក ព្រំ សុភមង្គល ជាជំនួយការ ឯកឧត្តម សម សុគ្គា ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...[illegible]

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន២៣រូប ដែលមានសទ្ធាជ្រះថ្លាចូលរួមចំណែកជួយកសាងព្រះវិហារ ឧបដ្ឋានសាលា កុដិ ខ្លោងទ្វារ របងវត្ត ស្រះទឹក និងសមិទ្ធផលនានាជាច្រើនទៀត នៅក្នុងពុទ្ធសីមា*វត្តព្រៃជុំ* ឃុំយុទ្ធសាមគ្គី ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | |
|---|---|
| ១-ព្រះតេជគុណ **សុវណ្ណ បញ្ញា** នៅ សារ៉ាត់ | បច្ច័យ ចំនួន ១០.៥០០ ដុល្លារ |
| ២-ព្រះតេជគុណ **ផាន់ គីន** ចៅអធិការ *វត្តព្រៃជុំ* | បច្ច័យ ចំនួន ១០.២០០ ដុល្លារ |
| ៣-លោក **ឧត្តី ពៅ** និងលោកស្រី **គេច ចំឡងឹឡូពៅ** | ថវិកា ចំនួន ៥០.៦៥០ ដុល្លារ |
| ៤-លោកស្រី **តាំង ហេងសល់** | ថវិកា ចំនួន ២៩.៨១០ ដុល្លារ |
| ៥-លោកស្រី **លី គីមហ៊ុន** | ថវិកា ចំនួន ១១.១០០ ដុល្លារ |
| ៦-ឧបាសិកា **ស៊ីនុត្តា សួន** | ថវិកា ចំនួន ១៩.៨០០ ដុល្លារ |
| ៧-លោកស្រី **គី មួច** | ថវិកា ចំនួន ១៧.៣០០ ដុល្លារ |
| ៨-លោក **សួន តារាឧត្ត** | ថវិកា ចំនួន ១១.២០០ ដុល្លារ |
| ៩-លោកស្រី **យឹម សាមីន** | ថវិកា ចំនួន ១០.៤០០ ដុល្លារ |
| ១០-លោក **មស ម៉ូច** | ថវិកា ចំនួន ១២.២០០ ដុល្លារ |
| ១១-លោក **នោរ ឈឹម** និងអ្នកស្រី **គី ម៉ុច** នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ៤៦.៤១០ ដុល្លារ |
| ១២-លោក **លី ច្មអាន** និងអ្នកស្រី **តាំង ហេងសល់** នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ២២.៣២០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ព្រំ សេង** និងអ្នកស្រី **យឹម សាមីន** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៧.០០០ ដុល្លារ

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | |
|---|---|
| ១-លោកតា **សេង ចិន** | ថវិកា ចំនួន ៤.១០០ ដុល្លារ |
| ២-ឧបាសិកា **នៅ ឡៃ** | ថវិកា ចំនួន ៣.០០១ ដុល្លារ |
| ៣-ឧបាសិកា **ម៉ន សឿន** | ថវិកាចំនួន ៣.០២១ ដុល្លារ |
| ៤-ឧបាសិកា **សំ សិន** | ថវិកា ចំនួន ៣.២០០ ដុល្លារ |
| ៥-លោកអាចារ្យ **ជៀម ខួត** | ថវិកា ចំនួន ៣.៣០០ ដុល្លារ |
| ៦-លោក **ពេជ្រ វង្សសេង** | ថវិកា ចំនួន ២.២០០ ដុល្លារ |
| ៧-លោក **គីម ចម** | ថវិកា ចំនួន ២.១៥០ ដុល្លារ |
| ៨-លោក **សួង លុយ** | ថវិកា ចំនួន ២.៧៣៤ ដុល្លារ |
| ៩-លោក **គង់ លាស់** | ថវិកា ចំនួន ៣.០៧០ ដុល្លារ |
| ១០-លោក **សាយ សារឿន** | ថវិកា ចំនួន ៣.០០០ ដុល្លារ |

ប្រការ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ៦ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៣៨០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូននាយទាហាន និងមន្ត្រី នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ចំនួន ១៤រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយបណ្តុះបណ្តាល និង អភិវឌ្ឍន៍កងឯកភាពអង្គរក្ស នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

| | |
|---|---|
| 1- Col. Andric T.U. Sutarno | MDS Defense Attache |
| 2- Mrs Syukraini Rahmawati | |
| 3- Col. Yudhi Agustino | Assistant of Logistic |
| 4- Col. Edy Ismayadi | Assistant of Security |
| 5- Col. Angger Waspodo | Assistant of Personal |
| 6- Col. Cpm Edi Ismayadi | Asintel Paspampres |
| 7- Col. Inf Pandu Wibowo | Assistant of Operation |
| 8- Lietcol . Dony Munardo | Deputy of Operation |
| 9- Major Budi Handoyo | ( គ្រូបង្វឹក ) |
| 10- Captain Sopriyadi | ( គ្រូបង្វឹក ) |

11- Lieutenant Sokandar ( គ្រូបង្វឹក )

12- First Sergent Risman Batubara ( គ្រូបង្វឹក )

13- First Sergent Diah Retno ( គ្រូបង្វឹក )

14-Mr. Bambang Soewondho Indonesian Supervision

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៥ ឆ្នាំ ២០០៦*

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ...៣៨១...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសាលាពុទ្ធិកវិទ្យាល័យ ***សាសាន ជា ឆោម*** បន្ទប់អនាម័យ និងអាងស្តុកទឹក នៅក្នុងពុទ្ធសីមា ***វត្ត រដ្ឋបាលារាម (ហៅវត្តចាំឆា)*** ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ម៉ុន ឈើន** ព្រះមេគណខេត្តក្រចេះ បច្ច័យចំនួន ១០.៧០០ ដុល្លារ
២-ព្រះតេជគុណ **ឆេព ចាន្ថា** នាយកសាលាពុទ្ធិកវិទ្យាល័យសាសានជាឆោម និងជាប្រធានសហគមន៍ទូទាំងខេត្តក្រចះ រួមកសាងចំនួន ១០.៦០០ ដុល្លារ
៣-ព្រះតេជគុណ **គ្រឿង រតនា** បច្ច័យចំនួន ១៣.៥០០ ដុល្លារ
៤-ព្រះតេជគុណ **យុន លីហេង** បច្ច័យចំនួន ១១.០០០ ដុល្លារ

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ជន ស៊ីអ៊ឹម** អនុគណស្រុកក្រចេះ បច្ច័យចំនួន ៥.៥០០ ដុល្លារ
២-លោក **នូ ចន្ទតារា** ថវិកាចំនួន ៥.៥០០ ដុល្លារ
៣-លោក **ពូជ សំប៊ុន** និង លោកស្រី **ហ៊ួ គីមយី** ថវិកាចំនួន ៥.៥៣០ ដុល្លារ

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ចាន់** | **សុផាត** | ថវិកាចំនួន ៤.៣០០ ដុល្លារ |
| ២-លោក | **ជ្រឹំ** | **សៅឫទ្ធារ៉ា** | ថវិកាចំនួន ៤.២៥០ ដុល្លារ |
| ៣-លោកស្រី | **ម៉ុក** | **សុខជា** | ថវិកាចំនួន ៣.៥០០ ដុល្លារ |
| ៤-លោក | **ឃឹម** | **វណ្ណនោ** | ថវិកាចំនួន ៣.៣៥០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៩២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង ព្រះវិហារ កុដិ សាលាបុណ្យ របង ខ្លោងទ្វារ និងសមិទ្ធផលនានាមួយចំនួនទៀត នៅវត្តឈើទាល ឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ខឹម ឌីន** | ចៅអធិការវត្តឈើទាល | បច្ច័យ ចំនួន ១១.៨៥០ ដុល្លារ |
| ២-លោកស្រី | **ស៊ាប សុចំន្ទ** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកា ចំនួន ១១.០០០ ដុល្លារ |
| ៣-ឧបាសក | **ប្រាក់ សឿន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកា ចំនួន ១០.៨០០ ដុល្លារ |

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣៧៤៣ អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន១៤គ្រឿង ប្រគេន និងជូនសប្បុរសជន ចំនួន១៤រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកា ចូលរួមជួយកសាងសាលារៀន សាលាធម្មសភា កុដិ និងសមិទ្ធផលនានាជាច្រើនទៀត នៅក្នុងពុទ្ធសីមា ***វត្តធម្មាចក្ការាម*** ភូមិអូរធ្លាតពង ឃុំគុត្តសត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **តិម សូផា** | ចៅអធិការ | បច្ច័យចំនួន ១៥.៥០០ ដុល្លារ |
| ២-ព្រះតេជគុណ | **សែម សុវណ្ណ** | | បច្ច័យចំនួន ១៥.៥០០ ដុល្លារ |
| ៣-ឧបាសក | **ប៊ុន ឱវ៉ានថា** | នៅប្រទេសបារាំង | ថវិកា ចំនួន ១៥.៥០០ ដុល្លារ |
| ៤-លោកយាយ | **បូផា ណយ ខាំ ស៊ី** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១៥.៥០០ ដុល្លារ |
| ៥-លោកតា | **ខាំ ម៉ា ឃុន** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១១.០០០ ដុល្លារ |
| ៦-លោកយាយ | **ខាំ ចាក់ប៊ុន្នី** | នៅប្រទេសស្វីស | ថវិកា ចំនួន ១១.០០០ ដុល្លារ |
| ៧-លោក | **លីម ហេង** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១១.០០០ ដុល្លារ |
| ៨-លោក | **ឈិន ផុង** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០០០ ដុល្លារ |
| ៩-លោក | **ខែម សូ និងអ្នកស្រី ធីតា** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.១៣០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ថង ឡានះ** ថវិកា ចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **ព្រំ អែត** ថវិកា ចំនួន ៣.៥០០ ដុល្លារ

២-លោក **សែ ម៉ុនមី** ថវិកា ចំនួន ៣.៥០០ ដុល្លារ

៣-លោក **សែ ថន** ថវិកា ចំនួន ១.៥០០ ដុល្លារ

៤-លោក **លៀម ខាំណាយ** ថវិកា ចំនួន ១.៥០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៨៤ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន១២គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ១២រូប ដែលបានជួយកសាងកុដិថ្មី និងរោងបាយ ព្រមទាំងជួសជុលកុដិចាស់ និងបណ្ណាល័យ នៅវត្តសារាវ័នតេជោ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

**ក. មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះឃោសាវិសុទ្ធិ | **ស៊ឹម សយ៉ុង** | ព្រះចៅអធិការវត្តសារាវ័នតេជោ | បច្ច័យចំនួន ១៤.៩០០ ដុល្លារ |
| ២-ភិក្ខុ | **ហួរ គីមហាន** | ព្រះវិន័យធរវត្តសារាវ័នតេជោ | បច្ច័យចំនួន ៦០.២៤៤ ដុល្លារ |
| ៣-ភិក្ខុ | **ថុល ធីរ** | គ្រូសូត្រឆ្វេងវត្តសារាវ័នតេជោ | បច្ច័យចំនួន ១១.៩៥៦ ដុល្លារ |
| ៤-លោកវរសេនីយ៍ឯក | **ម៉ែន រ័ត្ន** | សប្បុរសជន | ថវិកាចំនួន ៣២.៧៣៥ ដុល្លារ |
| ៥-លោកស្រី | **រ័ត្ន សុខា** | សប្បុរសជន | ថវិកាចំនួន ១១.៨២៥ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ភិក្ខុ | **យ៉ុន សចិន្តា** | គ្រូសូត្រស្តាំវត្តសារាវ័នតេជោ | បច្ច័យចំនួន ៨.០០៥ ដុល្លារ |
| ២-ភិក្ខុ | **ឆេង ឆវណ្ណនី** | លេខាធិការវត្តសារាវ័នតេជោ | បច្ច័យចំនួន ៨.១៤០ ដុល្លារ |
| ៣-ភិក្ខុ | **ខៀវ សំអាង** | គង់នៅប្រទេសឥណ្ឌា | បច្ច័យចំនួន ៨.២៨៥ ដុល្លារ |

| | | | |
|---|---|---|---|
| ៤-ភិក្ខុ | **មុំ ចិន្តា** | គង់នៅប្រទេសឥណ្ឌា | បច្ច័យចំនួន ៨.១១៥ ដុល្លារ |
| ៥-ភិក្ខុ | **យិម ម៉ៅ** | ប្រធានការកសង្សវត្តសារាវ៉ែនតេជោ | បច្ច័យចំនួន ៨.០៩៨ ដុល្លារ |
| ៦-ភិក្ខុ | **ម៉ៅ សុគន្ធី** | លេខាការកសង្សវត្តសារាវ៉ែនតេជោ | បច្ច័យចំនួន ៨.០៥០ ដុល្លារ |
| ៧-ឧបាសក | **ម៉ាង សន** | សប្បុរសជន | ថវិកា ចំនួន ៨.០២០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ , ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៩៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

~~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៦ ស្តីពីការដំឡើងអង្គភាពផលិតភាពទៅជាមជ្ឈមណ្ឌលផលិតភាពជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សម្រេច

**មាត្រា១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **យា ប៊ុនណា** ឋានន្តរស័ក្តិអនុមន្ត្រីថ្នាក់លេខ ១១ ឱ្យបំពេញមុខងារជាប្រធានមជ្ឈមណ្ឌលផលិតភាពជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ
~~~~~~~~~

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៥០១......សហវ.ប្រក. 

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការអនុវត្តន៍វិធីសាស្ត្រលទ្ធកម្មសាធារណៈ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.កប ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញប្រកាសលេខ ៣១៩ សហវ.ប.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តនីតិវិធាន និងបទប្បញ្ញត្តិក្នុការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តនីតិវិសហមជ្ឈការលទ្ធកម្មសាធារណៈ

-យោងកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសដាក់អោយអនុវត្តជាផ្លូវការនា ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៤

## សំរេច

ប្រការ ១ : ប្រកាសនេះមានគោលបំណងកែសំរួល និង បំពេញបន្ថែមខ្លឹមសារមួយចំនួនក្នុងប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃ ទី ៣១ ខែ មករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ។

ប្រការ ២ : ប្រការ២ នៃប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈត្រូវបានកែសំរួលដូចខាងក្រោម :

កំណត់វិធីសាស្ត្រលទ្ធកម្មតាមកំរិតទឹកប្រាក់ :

-ទឹកប្រាក់ក្រោម ២០លានរៀល អនុវត្តវិធីសាស្ត្រស្ទង់តំលៃ (Canvassing)

-ទឹកប្រាក់ចាប់ពី ២០លានរៀល ដល់ក្រោម ៥០លានរៀល អនុវត្តវិធីសាស្ត្រពិគ្រោះតំលៃ (Shopping)

-ទឹកប្រាក់ចាប់ពី ៥០លានរៀលឡើងទៅ អនុវត្តវិធីសាស្ត្រដេញថ្លៃជាសាធារណៈ ។

ប្រការ ៣ : ស្ថាប័នអនុវត្តលទ្ធកម្ម អាចចុះកិច្ចសន្យាផ្ទាល់ (Direct Contracting .DCo) ជាមួយអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការបាន ក្នុងករណីពិសេសណាមួយដូចខាងក្រោម :

១-ឧបករណ៍ដែលត្រូវការមានប្រភពតែមួយគត់

២-ករណីចាំបាច់សំរាប់ឆ្លើយតបនៅពេលមានគ្រោះមហន្តរាយធម្មជាតិកើតឡើង ហើយតម្រូវការចាំបាច់បន្ទាន់ ។

៣-សំរាប់គោលបំណងសិក្សា ស្រាវជ្រាវដកបទពិសោធន៍ ឬ អភិវឌ្ឍន៍

រាល់ការចុះកិច្ចសន្យាផ្ទាល់ទាំងអស់ ត្រូវមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៤ : រាល់បទប្បញ្ញត្តិទាំងឡាយណាពាក់ព័ន្ធក្នុងកិច្ចលទ្ធកម្មសាធារណៈ សំរាប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និង សហគ្រាសសាធារណៈ ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ ព្រមទាំងនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជ្រាបជារបាយការណ៍"
-ដូចប្រការ ៥
"ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្ត

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ....៤០៦...សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រង តែមប្រិ៍ទិដ្ឋាការ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល-ចេញ និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យ របស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- បានឃើញសារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការរៀបចំសេចក្តី-ព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៦
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញសារាចររបស់រាជរដ្ឋាភិបាល លេខ ០៦ សរ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការកែទំរង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសស្តីពីការប្រមូលចំណូលទិដ្ឋាការលេខ ៣០៤ សហវ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០១
- បានឃើញចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០១ លើលិខិតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៩៤១៨ សហវ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០១
- បានឃើញប្រកាសលេខ ៨៦១ សហវ.ថហ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីវិធានការគ្រប់គ្រងតែមប្រិ៍ទិដ្ឋាការស្អិត
- យោងស្មារតីនៃការប្រជុំអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ធនាគារជាតិនៃកម្ពុជា ស្តីពីយន្តការគ្រប់គ្រង តែមប្រិ៍ទិដ្ឋាការនាថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦
- តាមការចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពីតែមប្រិ៍ទិដ្ឋាការ

## សំរេច

**ប្រការ១ :** តែមប្រិ៍ទិដ្ឋាការ ត្រូវបានគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ២ :** ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៦ តែមប្រិ៍ទិដ្ឋាការស្អិតមានពីរប្រភេទ គឺ :

<u>ប្រភេទទី ១</u> : មានផ្ទៃពណ៌បៃតងស្រស់សំរាប់ផ្តល់ឱ្យជនបរទេសធ្វើដំណើរចូលមកប្រទេសកម្ពុជា ដែលរំលេចដោយអក្សរឡាតាំងធំៗ A,B,C,D,E,T និង K ដែលជាកំណត់សំគាល់នៃប្រភេទតែមប្រិ៍ទិដ្ឋាការនិមួយៗ ស្របតាមមាត្រា ៤ នៃអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីបែបបទសំរាប់អនុវត្ត ចំពោះការអនុវត្តឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល-ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ។

<u>ប្រភេទទី ២</u> : មានផ្ទៃពណ៌ខៀវថ្លា ដែលមានអក្សរ EX នៅក្នុងផ្ទៃ សំរាប់ពន្យារទិដ្ឋាការការស្នាក់នៅក្នុងប្រទេសកម្ពុជា លើកលែងតែអក្សរ K ចេញ ។

**ប្រការ៣ :** តែមប្រិ៍ទិដ្ឋាការត្រូវតម្កល់ទុកនៅរតនាគារជាតិ ។ រតនាគារជាតិត្រូវធ្វើបញ្ជីសារពើភ័ណ្ឌតែមប្រិ៍ទិដ្ឋាការរៀងរាល់ត្រីមាស ដោយមានការចូលរួមពីនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ។ ដោយឡែកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ តែមប្រិ៍ទិដ្ឋាការរៀងរាល់ មុនដំណាច់ត្រីមាសផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នា.ចំណូលមិនមែនសារពើពន្ធ) ។ នាយកដ្ឋាន ចំណូលមិនមែនសារពើពន្ធ ត្រូវថតចម្លងមួយច្បាប់ផ្ញើជូនរតនាគារជាតិ ។

**ប្រការ៤ :** តែមប្រិ៍ទិដ្ឋាការត្រូវបានបោះពុម្ពបន្ថែម តាមសំណើរបស់ប្រធានរតនាគារជាតិ ក្រោយពេលពិនិត្យឃើញថាមានតម្រូវការចាំបាច់ក្នុងការបោះពុម្ព និងបានពិភាក្សាឯកភាពគ្នាជាមួយ នឹងនាយកដ្ឋាន ចំណូលមិនមែន-សារពើពន្ធ ព្រមទាំងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ក្រសួងមហាផ្ទៃ ។ យន្តការនៃការបោះពុម្ព និងបញ្ចូលឃ្លាំង នូវតែមប្រិ៍ទិដ្ឋាការ ត្រូវកំណត់ដោយគណៈកម្មការមួយដែលនឹងត្រូវបង្កើតឡើង ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៥** : រតនាគារជាតិត្រូវបញ្ចេញតែមប្រិ៍ទិដ្ឋាការ បន្ទាប់ពីមានសំណូមពររបស់អង្គភាពមានសមត្ថកិច្ច នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ក្រោយពីបានឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុហើយត្រូវផ្ញើឯកសារច្បាប់ចម្លងទាំងនេះ មកនាយកដ្ឋាន ចំណូលមិនមែនសារពើពន្ធមួយច្បាប់ ។

**ប្រការ៦** : ចំណូលពីតែមប្រិ៍ទិដ្ឋាការដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ប្រមូលបានត្រូវបង់ចូលថវិការដ្ឋត្រង់ទៅគណនីប្រាក់បញ្ញើចំណូលជារូបិយប័ណ្ណ ដុល្លាអាមេរិក បណ្តោះ-អាសន្នរបស់សាមីក្រសួងនីមួយៗ នៅធនាគារជាតិនៃកម្ពុជា ។ ក្រសួងសាមី ត្រូវសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបើកគណនីប្រាក់បញ្ញើបណ្តោះអាសន្ននេះ នៅធនាគារជាតិនៃកម្ពុជា ។

ទឹកប្រាក់ដែលបានកត់ត្រាបញ្ចូលក្នុងគណនីបណ្តោះអាសន្ន មិនអាចដកយកទៅប្រើប្រាស់វិញបានទេ ។ ធនាគារជាតិ ត្រូវផ្ទេរដោយស្វ័យប្រវត្តិនូវសមតុល្យរបស់គណនីខាងលើទាំងនេះ ទៅគណនីលេខ ០១០២-៣៥.១២១១-T០២៣ របស់រតនាគារជាតិនៅរៀងរាល់ចុងថ្ងៃនីមួយៗ ហើយត្រូវជូនដំណឹងទៅសាមីក្រសួង ។ ក្រោយពីបានទទួលដំណឹងពីធនាគារជាតិនៃកម្ពុជា សាមីក្រសួងត្រូវផ្ញើសលាកប័ត្រចំណូលជាបន្ទាន់ទៅរតនាគារជាតិ ។

**ប្រការ៧** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៨** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ប្រធានរតនាគារជាតិ ព្រមទាំងប្រធានអង្គភាពពាក់ព័ន្ធចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពី ថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៦

គាត ឈន់

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាពត៌មាន"
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ធនាគារជាតិនៃកម្ពុជា
  " ដើម្បីសហការអនុវត្តន៍ "
- ឯកសារ និង កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព

លេខ :......១៣២......បទ.ប្រក

# ប្រកាស

## ស្តីពីការ បង្កើតក្រុមការងារ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញលិខិតលេខ ៣៦ សសរ ចុះថ្ងៃ ២២ ខែ ឧសភា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារមួយ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដើម្បីសហការ ការងារ ជាមួយក្រុមការងារទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការត្រួតពិនិត្យ និង ឃ្លាំមើលទៅលើសកម្មភាព និងលទ្ធផលអនុវត្តការងារ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលមាន សមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | ឡា | ណារ៉ាត | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | ទូច | ហេង | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | មាស | ប៉ូ | អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៤-ឯកឧត្តម | ព្រុំ | សុន្ទារ | អគ្គនាយករដ្ឋបាល | សមាជិក |

...ាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០/៤២៦៥១០
ទូរសារ: (៨៥៥) ២៣-៤២៦៩៩២/៤២៦០១១

HC:14

| | | | |
|---|---|---|---|
| ៥-លោក | **កែវ វុឌ្ឍិន** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៧-លោក | **ញាណ ស្រស់** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៧-លោក | **ទេព ប៊ុន្នា** | ប្រធាននាយកដ្ឋានផែនការហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២ :** ក្រុមការងារ ខាងលើនេះ មានភារកិច្ច :

-សហការការងារជាមួយ ក្រុមការងារ ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីត្រួតពិនិត្យ និង ឃ្លាំមើលទៅលើ សកម្មភាព និងលទ្ធផលអនុវត្តការងារ របស់ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

-ចប់ភារកិច្ច ត្រូវរាយការណ៍ពីលទ្ធផលការងារ ជូន ***ឯកឧត្តមរដ្ឋមន្ត្រី*** ។

**ប្រការ ៣ :** ក្រុមការងារខាងលើ នេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ ***ឯកឧត្តមប្រធាន*** និង ចាត់តាំងអនុគណៈកម្មការជំនាញផ្សេងទៀត តាមការងារចាំបាច់ ។

**ប្រការ ៤ :** រាល់ប្រកាសទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍ នាយកដ្ឋានពាក់ព័ន្ធ និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្ត ឱ្យមានប្រសិទ្ធិខ្ពស់ តាមខ្លឹមសារ នៃ ប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

**រដ្ឋមន្ត្រី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៥ " ដើម្បីអនុវត្ត "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខៈ១០៦៧ អយក.ប្រក

# ប្រកាស

ស្តីពីការប្តូរឈ្មោះ វិទ្យាល័យ "**វិហារសួគ៌**" ទៅជា

វិទ្យាល័យ "**អួន ពន្ធ័មុនីរ័ត្ន វិហារសួគ៌**"

ស្ថិតនៅក្នុង ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ចុះថ្ងៃទី ១៦ មករា ២០០៦ ដោយមានយោបល់ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កណ្តាល
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យប្តូរឈ្មោះ វិទ្យាល័យ "**វិហារសួគ៌**" បច្ចុប្បន្ន ទៅជាវិទ្យាល័យ "**អួន ពន្ធ័មុនីរ័ត្ន វិហារសួគ៌**" ស្ថិតនៅក្នុង ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កណ្តាល និងនាយកវិទ្យាល័យ សាមីមានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៦

បណ្ឌិត កិត្តិ ផេង

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្ត កណ្តាល "ដើម្បីជាពត៌មាន"
- ដូចប្រការ៣
- កាលប្បវត្តិ-ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ:១០៦១ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកអនុវិទ្យាល័យ " ភ្នំដែក "
## ស្ថិតនៅក្នុង ឃុំ រមណីយ៍ ស្រុក រវៀង ខេត្ត ព្រះវិហារ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ រមណីយ៍ ស្រុក រវៀង ចុះថ្ងៃទី ២៩ តុលា ២០០៥ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត ព្រះវិហារ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

### សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **ភ្នំដែក** " ស្ថិតនៅក្នុង ឃុំ រមណីយ៍ ស្រុក រវៀង ខេត្ត ព្រះវិហារ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

**ប្រការ ២** : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ។

**ប្រការ ៤** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ព្រះវិហារ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ២០០៦

បណ្ឌិត គុល ផេង

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលា ខេត្ត ព្រះវិហារ " ដើម្បីជាពត៌មាន "
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ: ១០៦៧ អយក.ប្រក**

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " **រស្មី រីករាយ** "

ស្ថិតនៅក្នុង ឃុំ រស្មី ស្រុក រវៀង ខេត្ត ព្រះវិហារ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ រស្មី ស្រុក រវៀង ចុះថ្ងៃទី ២៨ វិច្ឆិកា ២០០៥ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត ព្រះវិហារ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **រស្មី រីករាយ** " ស្ថិតនៅក្នុង ឃុំ រស្មី ស្រុក រវៀង ខេត្ត ព្រះវិហារ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

**ប្រការ ២** : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ។

**ប្រការ ៤** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ព្រះវិហារ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៦

បណ្ឌិត កុល ផេង

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលា ខេត្ត ព្រះវិហារ "ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

❀❀❀❀❀❀❀

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ:១០៦៣ អយក.ប្រក**

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ “ **រអាង** ”

ស្ថិតនៅក្នុង ឃុំ រអាង ស្រុក សង្គមថ្មី ខេត្ត ព្រះវិហារ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ រអាង ស្រុក សង្គមថ្មី ចុះថ្ងៃទី ២៧ វិច្ឆិកា ២០០៥ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត ព្រះវិហារ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ “ **រអាង** ” ស្ថិតនៅក្នុង ឃុំ រអាង ស្រុក សង្គមថ្មី ខេត្ត ព្រះវិហារ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

**ប្រការ ២** : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ព្រះវិហារ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី០៩ ខែ មិថុនា ឆ្នាំ២០០៦

បណ្ឌិត កុល ផេង

**កន្លែងទទួល:**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ “ដើម្បីជ្រាបជាពត៌មាន”
- -សាលា ខេត្ត ព្រះវិហារ “ដើម្បីជាពត៌មាន”
- -ដូចប្រការ៤
- -កាលប្បវត្តិ-ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៩៥៩ ពណ.នតក

ភ្នំពេញថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហាន អ៊ិនវេសមេន ភីធីអ៊ាយ អិលធីឌី**

**HAN INVESTMENTS PTY LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8597/06P** ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ហាន ស៊ីអៀង** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ខែ ណារិន** អភិបាល
លោកស្រី **គុយ ហួច** អភិបាល
លោកស្រី **លឹម ឃី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២០៥ ផ្លូវប៉ាស្ទ័រ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
